# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការមួយឈ្មោះថា " គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ " ដែលមានឈ្មោះជាអក្សរកាត់ថា "គ.ជ.វ.វ"

និងមានឈ្មោះជាភាសាអង់គ្លេសថា " **National Committee for the Management of Decentralization and Deconcentration Reform (NCDD)** "។

## ជំពូកទី ២
## សមាសភាព និងបេសកកម្ម

**មាត្រា ២ ..**

គ.ជ.វ.វ នេះមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ជាសមាជិក |
| ៧- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងមហាផ្ទៃមួយរូប | ជាសមាជិកអចិន្ត្រៃយ៍ |

គ.ជ.វ.វ អាចអញ្ជើញរដ្ឋមន្ត្រីក្រសួងផ្សេងៗទៀតចូលរួមប្រជុំតាមការចាំបាច់។

សមាជិកម្នាក់ៗរបស់ គ.ជ.វ.វ អាចតែងតាំងតំណាងមួយរូបដែលជាសមាជិករាជរដ្ឋាភិបាល ដើម្បីជំនួសខ្លួននៅក្នុងការចូលរួមកិច្ចប្រជុំទាំងអស់ ឬកិច្ចប្រជុំណាមួយ ដោយផ្តល់អំណាចឱ្យតំណាងរូបនោះអាចមានសិទ្ធិសម្រេចជំនួសសមាជិកនោះ។

**មាត្រា ៣ ..**

គ.ជ.វ.វ មានបេសកកម្មសំខាន់ៗដូចខាងក្រោម ÷

- បន្តមុខងារ និងភារកិច្ចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមុខងារនិងភារកិច្ចទាំងនោះត្រូវប្រចាប់បញ្ចូលជាស្វ័យប្រវត្តិទៅក្នុងការទទួលខុសត្រូវ និងសមត្ថកិច្ចរបស់ គ.ជ.វ.វ។

- សិក្សាស្រាវជ្រាវ និងអនុវត្តនូវយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់ការធ្វើអន្តរកាល ការប្រចាប់បញ្ចូល និងការវិសាយកម្មវិធីសិលាជាបណ្តើរៗ បន្ទាប់ពីកម្មវិធីនេះត្រូវបញ្ចប់នៅដំណាច់ឆ្នាំ២០០៦។

- គាក់តែង និងអនុវត្តកម្មវិធីជាតិជាបឋមសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ។

- រៀបចំ និងអនុម័តនូវក្របខ័ណ្ឌជាបឋមសម្រាប់អនុវត្តមួយដែលមានចែងពីសមាសភាគ កាលបរិច្ឆេទ និងសកម្មភាពបណ្តោះអាសន្ននានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងអំឡុងពេលរង់ចាំការប្រកាសឱ្យប្រើនូវច្បាប់អង្គការ។

- សិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ក្នុងការបង្កើត នូវមូលនិធិសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដ៏សមស្របមួយ ដើម្បីប្រមូលផ្តុំ ប្រភពធនធានម្ចាស់ជំនួយនានា សម្រាប់តម្រូវការផ្នែកបុគ្គលិក និងកិច្ចសហប្រតិបត្តិការរបស់ គណៈកម្មាធិការជាតិ ការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងតម្រូវការចាំបាច់នានានៅថ្នាក់ ក្រោមជាតិ ព្រមទាំងការផ្តល់ជំនួយបច្ចេកទេសដល់ក្រសួងពាក់ព័ន្ធនានា។

- ស្រាវជ្រាវ ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលអំពីជម្រើសដ៏ល្អ បំផុតនៃការកៀរគរមូលនិធិអន្តរជាតិសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

- ស្រាវជ្រាវ និងរៀបចំនូវកិច្ចព្រមព្រៀងមួយរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយស្តីពី ការគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាថាគ្រប់ម្ចាស់ជំនួយទាំងអស់ត្រូវ តែជាភាគីនៃកិច្ចព្រមព្រៀងនេះ ដែលជាការធានានូវការតម្រឹមជំនួយ។

- ធានាឱ្យមានការសម្របសម្រួល និងការពិភាក្សាយ៉ាងគ្រប់គ្រាន់ក្នុងចំណោម គ.ជ.វ.វ ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ក្នុងការផ្ទេរមុខងារ អំណាច និងធនធានពីថ្នាក់ជាតិទៅថ្នាក់ ក្រោមជាតិ។

- បង្កើតនូវវេទិកាដ៏សមស្របមួយរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយសម្រាប់សម្រប សម្រួលកិច្ចសហប្រតិបត្តិការ និងការកៀរគរជំនួយសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ។

**មាត្រា ៤ ..**

គ.ជ.វ.វ អាចស្នើឱ្យក្រសួង ឬស្ថាប័នជាតិណាមួយផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តន៍ តាមកម្មវិធីជាតិជាបឋម ព្រមទាំងអាចស្នើឱ្យស្ថាប័ននោះអនុវត្តដោយអនុលោមតាមកាលបរិច្ឆេទ ដែលបានកំណត់យ៉ាងច្បាស់លាស់ដោយ គ.ជ.វ.វ។

**មាត្រា ៥ ..**

គ.ជ.វ.វ ចេញសេចក្តីសម្រេច និងសេចក្តីណែនាំនានាផ្អែកតាមសមត្ថកិច្ច និងការទទួល ខុសត្រូវដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

**មាត្រា ៦ ..**

ផ្អែកតាមសមត្ថកិច្ចរបស់ខ្លួន គ.ជ.វ.វ អាចស្នើយោបល់ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្របតាមនីតិវិធីជាធរមាន។

**មាត្រា ៧ .-**

គ.ជ.វ.វ ត្រូវប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៨ .-**

គ.ជ.វ.វ នឹងបញ្ចប់អាណត្តិរបស់ខ្លួនក្នុងពេលដែលយន្តការមួយសម្រាប់ដឹកនាំការអនុវត្តន៍ច្បាប់អង្គការត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់អង្គការ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ របៀបរបបការងារ និងលេខាធិការដ្ឋាន

**មាត្រា ៩ .-**

គ.ជ.វ.វ មានសិទ្ធិបង្កើតអនុគណៈកម្មការនានាតាមការចាំបាច់ដើម្បីជាជំនួយការលើផ្នែកជំនាញនីមួយៗរបស់ខ្លួន។

**មាត្រា ១០ .-**

គ.ជ.វ.វ ត្រូវជួបប្រជុំសាមញ្ញរៀងរាល់ពីរខែម្តង។

គ.ជ.វ.វ អាចធ្វើការប្រជុំវិសាមញ្ញបានតាមការចាំបាច់ តាមការស្នើសុំរបស់ប្រធាន និងសមាជិកពីររូបនៃ គ.ជ.វ.វ។

គ.ជ.វ.វ ត្រូវរៀបចំ និងអនុម័តនូវនីតិវិធីការងាររបស់ខ្លួន។

**មាត្រា ១១ .-**

ត្រូវបានបង្កើតក្រុមការងារមួយសម្រាប់ជាជំនួយការឱ្យ គ.ជ.វ.វ ដែលនឹងកំណត់ដោយអនុក្រឹត្យ ។

ក្រុមការងារនេះអាចអញ្ជើញតំណាងក្រសួងផ្សេងៗទៀតឱ្យចូលរួមពិភាក្សា និងបំពេញការងារតាមការចាំបាច់។

ក្រុមការងារមានភារកិច្ចណែនាំ សម្របសម្រួលការងារចន្លោះពីការប្រជុំមួយទៅការប្រជុំមួយទៀតរបស់ គ.ជ.វ.វ ទៅតាមការសម្រេចរបស់ គ.ជ.វ.វ។

តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ក្រុមការងារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.វ.វ។

**មាត្រា ១២ .-**

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ត្រូវយកអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ធ្វើជាលេខាធិការដ្ឋាន។

លេខាធិការដ្ឋានត្រូវបំពេញរាល់កិច្ចការចាំបាច់ ដើម្បីធានាការបំពេញមុខងាររបស់ គ.ជ.វ.វ និងក្រុមការងារឱ្យបានសមស្រប។

## ជំពូកទី ៤
## ប្រភពធនធានថវិកា

**មាត្រា ១៣ ..**

គ.ជ.វ.វ ត្រូវមានគម្រោងថវិកាដើម្បីបំពេញការងាររបស់ខ្លួនដែលសមស្របនឹងតម្រូវការនានានៃក្របខ័ណ្ឌជាបឋមសម្រាប់អនុវត្ត។

គ.ជ.វ.វ អាចទទួលជំនួយផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារៈពីប្រភពក្នុងប្រទេស និង ក្រៅប្រទេសសម្រាប់អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៥ ..**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងសមាសភាពដូចមានចែងក្នុងមាត្រា២ និង មាត្រា១១ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នសល.០៨០៦.៣៧៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ៣៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**